មាត្រា ៤ : អគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទត្រូវទទួលបន្ទុកអនុវត្តន៍អនុក្រឹត្យនេះ ។

មាត្រា ៥ : អនុក្រឹត្យនេះចូលជាធរមានចាប់ពីពេលឡាយព្រះហស្ថលេខា និង ចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *

*រាជធានីភ្នំពេញ; ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ១៩៩៤*

## អនុក្រឹត្យ លេខ ៥៦ អនក្រ
## ស្តីពីការបង្កើតសេនាធិការដ្ឋាន
## កងរាជអាវុធហត្ថ ស្វាយរៀង ព្រៃវែង
## កណ្តាល កំពង់ឆ្នាំង កំពង់ស្ពឺ ស្ទឹងត្រែង

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃព្រះរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញក្រឹត្យចុះថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតសេនាធិការដ្ឋាន កងទ័ពជាតិកម្ពុជា ។

-ផ្អែកតាមសំណូមពរនៃការកសាងកងរាជអាវុធហត្ថ ឆ្នាំ ១៩៩៤ និងបង្កើនការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម បង្ក្រាបរាល់អំពើល្មើសច្បាប់។

-ផ្អែកតាមសំណើរបស់នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ ។

**សំរេច**

មាត្រា ១ : ត្រូវបានបង្កើតសេនាធិការដ្ឋាន កងរាជអាវុធហត្ថ ស្វាយរៀង ព្រៃវែង កណ្តាល កំពង់ឆ្នាំង កំពង់ស្ពឺ ស្ទឹងត្រែង ស្ថិតនៅក្រោម ការដឹកនាំ បញ្ជាផ្ទាល់របស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថ នៃអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ។

មាត្រា ២ : រចនាសម្ព័ន្ធចាត់តាំងភារកិច្ច និង សិទ្ធិរបស់សេនាធិការកងរាជអាវុធហត្ថ ស្វាយរៀង ព្រៃវែង កណ្តាល កំពង់ឆ្នាំង កំពង់ស្ពឺ ស្ទឹងត្រែង អាស្រ័យដោយអគ្គសេនាធិការកំណត់។

មាត្រា ៣ : ប្រគល់ជូនអគ្គសេនាធិការ កងយោធពលខេមរភូមិន្ទធ្វើការកំណត់ភារកិច្ច និងពេលវេលាជាក់ស្តែងក្នុងការរៀបចំសេនាធិការដ្ឋាន កងរាជអាវុធហត្ថខាងលើ។

មាត្រា ៤ : អគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទត្រូវទទួលបន្ទុកអនុវត្តន៍អនុក្រឹត្យនេះ ។

មាត្រា ៥ : អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីពេលឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *